# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្ដាហ៍ លេខ ៦៨

នាសប្ដាហ៍នេះ អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូប ស្ដីពីបទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ និងសាក្សីចំនួនពីររូបផ្សេងទៀត ពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុង។ នៅថ្ងៃចន្ទនាសប្ដាហ៍នេះ អ្នកស្រី **សា ឡាយហ៊ាង** បានផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តប៉ៃលិន ស្ដីពីបទពិសោធន៍របស់គាត់ដែលបានបដិសេធចំពោះការស្នើឲ្យគាត់រៀបការចំនួនពីរលើក ហើយក្រោយមកគាត់ក៏បានយល់ព្រមចំពោះការស្នើសុំជាលើកទីបីនេះ ដោយសារតែមានការភ័យខ្លាច នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលព្រឹកថ្ងៃអង្គារ សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី **មុំ វុន** ដែលធ្លាប់បានចាប់ផ្ដើមកាលពីសប្ដាហ៍មុននោះ បានឈានដល់ទីបញ្ចប់ដោយមានការចោទសួរដេញដោលពីសំណាក់ក្រុមមេធាវីការពារក្ដី។ នៅពេលរសៀលថ្ងៃអង្គារ កិច្ចដំណើរការនីតិវិធីសវនាការ បានបែរត្រឡប់មកផ្នែកជំនុំជម្រះស្ដីពីការបោសសម្អាតវិញ ដោយសាក្សីលោក **សែម អំ** បានផ្ដល់ភស្តុតាងពាក់ព័ន្ធនឹងការបោសសម្អាតនៅក្នុងកងពលលេខ៣១០ រួមទាំងការចាប់ខ្លួន **អឿន** និង **កុយ ធួន** ដែលជាលេខាភូមិភាគឧត្ដរ។ នៅចុងបញ្ចប់នាសប្ដាហ៍នេះ អង្គជំនុំជម្រះបានស្ដាប់សាក្សីមួយរូបទៀត **2-TCW-1036** ដែលបានផ្ដល់សក្ខីកម្មដោយប្រើប្រាស់ឈ្មោះជារហស្សនាក្រោមវិធានការណ៍ការពារ ស្ដីពីការបម្រើការងារឲ្យលេខាភូមិភាគពាយព្យ **រស់ ញឹម** និងការចាប់ខ្លួនគាត់នៅពេលក្រោយមកទៀតក្នុងឆ្នាំ១៩៧៧។ ភាគី ក៏បានធ្វើការជជែកពិភាក្សាគ្នាលើបញ្ហាគតិយុត្តជាច្រើនក្នុងសប្ដាហ៍នេះផងដែរ រួមមាន៖ វិសាលភាពនៃសំណុំរឿង០០២ វគ្គ២ និងការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណ

កម្ម។ នៅចុងបញ្ចប់នៃសប្ដាហ៍នេះ អង្គជំនុំជម្រះបានផ្អាកសវនាការរហូតដល់ថ្ងៃអង្គារ ទី៤ ខែតុលា ដើម្បីឈប់សម្រាកសម្រាប់ពិធីភ្ជុំបិណ្ឌ ដែលជាការឈប់សម្រាកប្រចាំឆ្នាំរបស់ប្រជាជនកម្ពុជា។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ម៉ាយខល ចេន (Michael Chen), ហាន់ណា ដេយឆ៍ (Hanna Daych), ម៉ាលេនី ហៃដ៍ (Melanie Hyde), ខេតលីន កាហ្វព្រៀ (Caitlin McCaffrie), និន វុទ្ធី, លូវីស រេតវាយលើ (Louise Rettweiler), តាយលីណា, ធំ ស្ថាពរ និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូលូលូ (Honolulu) និងមជ្ឈមណ្ឌលដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្ដួចផ្ដើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។